ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកោះកុង

សំណុំរឿងព្រហ្មទណ្ឌលេខ ២៥៥

ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩

<u>សាលក្រមព្រហ្មទណ្ឌ</u>

លេខ ៤៥ "ក"

ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០

## <u>គោរពនាមប្រជារាស្ត្រខ្មែរ</u>

## <u>សាលាដំបូងខេត្តកោះកុង</u>

បានបើកសវនាការជាសាធារណៈនៅសាលជំនុំជម្រះនៃសាលាដំបូងខេត្តកោះកុង នាថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ២:៣០នាទីរសៀល ដោយមានសមាសភាពដូចតទៅ៖

<u>ប្រធានក្រុមប្រឹក្សាជំនុំជម្រះ</u>

-លោក [redacted] ប្រធានសាលាដំបូងខេត្តកោះកុង

<u>ចៅក្រមប្រឹក្សា</u>

-លោក [redacted] អនុប្រធានសាលាដំបូងខេត្តកោះកុង

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តកោះកុង

<u>តំណាងអយ្យការ</u>

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកោះកុង

<u>ក្រឡាបញ្ជីសវនាការ</u>

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកោះកុង

<u>មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ</u>

-លោក [redacted]

-លោកស្រី [redacted]

-លោក [redacted]

<u>-ដើម្បីជំនុំជម្រះ</u> លើសំណុំរឿងព្រហ្មទណ្ឌលេខ:២៥៥ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ ដែលមានមានជនជាប់ចោទ: ឈ្មោះ [redacted] ប៊ុន ភេទប្រុស អាយុ ៦៥ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ សាសនាព្រះពុទ្ធ កំរិតវប្បធម៌ មិនចេះអក្សរ ទីកន្លែងកំណើតភូ[redacted] ខេត្តកោះកុង ទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តកោះកុង ឪពុកឈ្មោះ [redacted] ចេត (ស) ម្ដាយឈ្មោះ[redacted] ប្រាក់ (ស) ប្រពន្ធឈ្មោះ[redacted] ផុន (រ) មានកូន ០៩នាក់ ទោសពីមុន គ្មានជានីតិជន ។ (ឃុំខ្លួនថ្ងៃទី១២-០៨-២០១៩) ។

<u>*ជាប់ចោទពីបទ:*</u> កាប់គាស់ រុករាន ឆ្ការ និងដុតដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅតំបន់ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង ចំណុចរបៀងអភិរក្សជីវៈចម្រុះ ត្រង់និយាមកាលេខ: ៣៦១៣៤៣-១២៣៥២៧៩ នៅភូមិតាផង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៥៦ ចំណុច៤ និងមាត្រា ៦២ ចំណុច១



Scanned with CamScanner

នៃច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិ ។

-បានឃើញៈដីកាសន្និដ្ឋានស្ថាពរលេខៈ ២៨០ អយ/១៩ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកោះកុង ។

-បានឃើញៈដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខៈ ៣២១៧ អយ/១៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ចៅក្រមសាលាដំបូងខេត្តកោះកុង ។

-បានឃើញៈដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ១២ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ ២០២០ របស់ប្រធានសាលាដំបូងខេត្តកោះកុង ។

## អង្គហេតុ

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:**

-កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង ៧:៣០នាទី មន្ត្រីរបស់មន្ទីរបរិស្ថានខេត្តកោះកុង បានសហការណ៍ជាមួយកងកម្លាំងរាជអាវុធហត្ថលើផ្ទៃប្រទេស និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ បានចុះប្រតិបត្តិការបង្ក្រាបបទល្មើសធនធានធម្មជាតិ ត្រង់តំបន់ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង ចំណុចរបៀងអភិរក្សជីវៈចម្រុះ និយាមកាលេខៈ **៣៦១៣៤៣-១២៣៥២៧៩** ស្ថិតនៅភូមិតាផង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង ក៏បានឃើញមានការ **កាប់គាស់ រុករាន ឆ្ការ និងដុតដីព្រៃយកធ្វើជាកម្មសិទ្ធិ** ដែលបង្កឡើងដោយឈ្មោះ [redacted] ប៊ុន ដែលមានផ្ទៃដីទំហំ **០,៣៥ (សូន្យ *ក្បៀសសាមសិបប្រាំ*) ហិកតា** ដែលទើបតែកាប់រានថ្មីៗ និងមានការសង់រោងស្នាក់នៅបណ្តោះអាសន្ន ចំនួន **០២រោង** ព្រមទាំងមានដាំដំណាំមួយចំនួនផងដែរ ។ កន្លងមកខាងមន្ត្រីបរិស្ថានធ្លាប់បានចុះទៅណែនាំឈ្មោះ [redacted] ប៊ុន ឲ្យឈប់កាប់រានដីព្រៃបន្តទៀត តែឈ្មោះនោះមិនស្តាប់ ទើបសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនឈ្មោះ [redacted] ប៊ុន បញ្ជូនមកតុលាការតែម្តង ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុន បានឆ្លើយបញ្ជាក់ថាៈ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង ០៧ព្រឹក ខ្លួន និងប្រពន្ធកំពុងនៅផ្ទះ ស្ថិតនៅភូមិតាផង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង ស្រាប់តែសមត្ថកិច្ចមកដល់ហើយធ្វើការឃាត់ខ្លួន រូបខ្លួនតែម្តង ដោយពាក់ព័ន្ធនឹងបទល្មើសព្រៃឈើ ។ ដីដែលស្ថិតនៅចំណុចរបៀងជីវៈចម្រុះ ស្ថិតនៅក្នុងភូមិតាផង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង គឺខ្លួនបានកាន់កាប់រយៈពេល ៧ឆ្នាំមកហើយ ដីនោះមានចំនួន **២ក្បាលដី** គឺមានទំហំ **៤ហិកតា** និង**៦ហិកតា** ដែលមានទីតាំងផ្សេងពីគ្នា តែនៅជិតៗគ្នា សព្វថ្ងៃខ្លួនរស់នៅលើដីដែលមានក្បាលដី **៤ហិកតា** ចំណែកដីដែលមានក្បាលដី**០៦ហិកតា** គឺខ្លួនបានសង់កូនខ្ទមចំនួន **០២**ដែលមានដាំដើមស្វាយចន្ទីនិងដាំដូង។ ចំពោះដីទាំង **០២កន្លែង** នោះ គឺខ្លួនមិនមានលិខិតកាន់កាប់នោះទេ មានតែលិខិតស្នើសុំទៅអភិបាលខេត្ត ហើយក៏មានខាងសុរិយោដីស្រុកស្រែអំបិល ចុះមកវាស់វែងផងដែរ តែក្រោយពីការវាស់វែងខាងសុរិយោដីបានប្រាប់ថា មិនឲ្យខ្លួនកាន់កាប់ដីនោះទៀតទេ រងចាំលិខិតអនុញ្ញាតមកពីខាងអាជ្ញាធរសិន នៅអំឡុងឆ្នាំ២០១៩ខាងបរិស្ថានធ្លាប់បានចុះមកហាមឃាត់ខ្លួនមិនឲ្យធ្វើការកាប់ព្រៃឈើ តែក្រោយពេលដែលខាងបរិស្ថានចុះមកបានប្រហែលជា ០៥ ទៅ ០៦ថ្ងៃ ខ្លួនបានទៅកាប់ឆ្ការព្រៃជុំវិញដើមស្វាយចន្ទីអស់ដីប្រហែល **០៣អា** ខ្លួនបានដឹងថាការកាប់ព្រៃឈើជាអំពើល្មើសនឹងច្បាប់ ។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ថាន បានឆ្លើយបញ្ជាក់ថាៈ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង ៧:៣០នាទី ក្រុមមន្ត្រីរបស់មន្ទីរបរិស្ថានខេត្តកោះកុង បានសហការណ៍ជាមួយ

កងកម្លាំងរាជអាវុធហត្ថលើផ្ទៃប្រទេស និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ បានចុះប្រតិបត្តិការបង្ក្រាបបទល្មើសធនធានធម្មជាតិ ត្រង់តំបន់ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង ចំណុចរបៀងអភិរក្សជីវៈចម្រុះ និយាមកាលេខៈ **៣៦១៣៨៣-១២៣៥២៧៩** ស្ថិតនៅភូមិតាផង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង ក៏បានឃើញមានការ **កាប់ គាស់ រុករាន ឆ្ការ និងដុតដីព្រៃយកធ្វើជាកម្មសិទ្ធិ** ដែលបង្កឡើងដោយឈ្មោះ [redacted] ប៊ុន ដែលមានផ្ទៃដីទំហំ **០,៣៥ (សូន្យ *កណ្តក់សញ្ញា* សាមសិបប្រាំ) ហិកតា** ដែលទើបតែកាប់រានថ្មីៗ និងមានការសង់រោងស្នាក់នៅចំនួន **០២រោង** ព្រមទាំងមានដាំដំណាំមួយចំនួនផងដែរ ។ កន្លងមកខាងមន្ត្រីបរិស្ថានខ្លួនធ្លាប់បានចុះទៅណែនាំឈ្មោះ [redacted] ប៊ុន ឲ្យឈប់កាប់រានដីព្រៃបន្តទៀត តែឈ្មោះនោះមិនស្តាប់ ទើបសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនឈ្មោះ [redacted] ប៊ុន បញ្ជូនមកតុលាការតែម្តង ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] លីន បានឆ្លើយថាៈ ខ្លួនស្គាល់ឈ្មោះ [redacted] ប៊ុន ព្រោះគាត់ជាបងថ្លៃរបស់ខ្លួនហើយគាត់បានគ្រប់គ្រងដីនេះតាំងពីឆ្នាំ១៩៨២មកម្លេះហើយបានដាំដំណាំដូចជាៈ ស្រូវ និងដើមចន្ទី ហើយខ្លួនដឹងថាដីដែលបងថ្លៃខ្លួនកំពុងកាន់កាប់នេះមានទំហំ **០៦ហិកតា** ដោយគាត់បានដាក់ពាក្យស្នើសុំទៅខេត្តដើម្បីឲ្យចេញប្លង់រឹងហើយ ។ ខ្លួនមិនដឹងថា បងថ្លៃខ្លួនឈ្មោះ [redacted] ប៊ុន គាត់បានកាប់រានដីព្រៃជម្រកសត្វព្រៃនោះទេ ព្រោះខ្លួនឃើញគាត់ធ្វើស្រែចំការជារៀងរាល់ឆ្នាំ ហើយតាំងពីយូរណាស់មកហើយ ។ ចំពោះរឿងខាងបរិស្ថានបានចុះមកណែនាំគាត់រឿងកាប់រានដីព្រៃនោះ ខ្លួនមិនដឹងទេ ហើយខ្លួនក៏មិនបានដឹងរឿងអ្វីក្រៅពីនេះទៀតដែរ ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] ឿន និងឈ្មោះ [redacted] សំណាង បានឆ្លើយប្រហាក់ប្រហែលគ្នាថាៈ ខ្លួនស្គាល់ឈ្មោះ [redacted] ប៊ុន ប្រហែលជាង **២០ឆ្នាំ** មកហើយ ហើយគាត់មានដីចំការគាត់មានដាំដើមចន្ទីជាច្រើន និងជាយូរណាស់មកហើយ ហើយនៅក្បែរផ្ទះគាត់គឺមានដាំដើមអំពៅទៀតផង គាត់រស់នៅលើដីនោះតាំងពីយូរមកហើយ ។ ខ្លួនមិនដឹងថាសមត្ថកិច្ចចាប់ខ្លួនឈ្មោះ [redacted] ប៊ុន ពីរឿងអ្វីនោះទេ ហើយក៏មិនដឹងរឿងដែរ។ ខ្លួនធ្លាប់ឃើញមាន ខាងមន្ត្រីបរិស្ថានធ្លាប់ចុះមកផ្ទះរបស់ឈ្មោះ [redacted] ប៊ុន ម្តងដែរតែមិនដឹងពីរឿងអ្វីនោះទេ ខ្លួនក៏មិនបានដឹងរឿងអ្វីក្រៅពីនេះទៀតដែរ ។

-តាមអំណានចម្លើយឈ្មោះ [redacted] ធី បានឆ្លើយបញ្ជាក់ថាៈ ខ្លួនស្គាល់ឈ្មោះ [redacted] ប៊ុន ប្រហែលជាង **២០ឆ្នាំ** មកហើយ ហើយគាត់មានដីចំការគាត់មានដាំដើមចន្ទីជាច្រើន និងជាយូរណាស់មកហើយ ហើយនៅក្បែរផ្ទះគាត់គឺមានដាំដើមអំពៅទៀតផង គាត់រស់នៅលើដីនោះតាំងពីយូរមកហើយ។ ខ្លួនមិនដឹងថាសមត្ថកិច្ចចាប់ខ្លួនឈ្មោះ [redacted] ប៊ុន ពីរឿងអ្វីនោះទេ ហើយក៏មិនដឹងរឿងដែរ។ ខ្លួនធ្លាប់ឃើញមានខាងមន្ត្រីបរិស្ថានធ្លាប់ចុះមកផ្ទះរបស់ឈ្មោះ [redacted] ប៊ុន ម្តងដែរតែមិនដឹងពីរឿងអ្វីនោះទេ ខ្លួនក៏មិនបានដឹងរឿងអ្វីក្រៅពីនេះទៀតដែរ ។

-តំណាងអយ្យការនាពេលសវនាការបានធ្វើសេចក្តីសន្និដ្ឋានទោសថាៈ មានពិរុទ្ធភាព និង ភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទៈឈ្មោះ [redacted] ប៊ុន ភេទប្រុស អាយុ ៦៥ឆ្នាំ ជនជាតិខ្មែរ ***ពីបទៈ* កាប់គាស់ រុករាន ឆ្ការ និងដុតដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅតំបន់ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង ចំណុចរបៀងអភិរក្សជីវៈចម្រុះ ត្រង់និយាមកាលេខៈ **៣៦១៣៨៣-១២៣៥២៧៩** នៅភូមិតាផង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៥៦ ចំណុច៤ និងមាត្រា ៦២ ចំណុច១ នៃច្បាប់ស្តីពីតំបន់/



Scanned with CamScanner

**ការពារធនធានធម្មជាតិ** តាងនាមតំណាងអយ្យការ សូមរក្សាបទចោទប្រកាន់ទុកជាបានការពេញទាំងមូលដដែល តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: **២៨០ អយ/១៩** ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ និងស្នើសុំឲ្យតុលាការផ្តន្ទាទោស លើជនជាប់ចោទឈ្មោះ **ចេត ប៊ុន** ទៅតាមច្បាប់ ។

-លោក [redacted] , លោកស្រី [redacted] និងលោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted]ប៊ុន បានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្លួនឈ្មោះ [redacted]ប៊ុន ពិតជាបានប្រព្រឹត្តអំពើ **កាប់គាស់ រុករាន ឆ្ការ និងដុតដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ** ពិតមែន ហើយកូនក្តីខ្លួនបានឆ្លើយសារភាពដោយស្មោះត្រង់ហើយ ម្យ៉ាងទៀតកូនក្តីខ្លួនជាមនុស្សអវិជ្ជា ពុំបានពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយខ្លួនសំណូមពរសុំឲ្យតុលាការបន្ធូរបន្ថយទោសឲ្យកូនក្តីខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted]ប៊ុន បាននិយាយសំដី និងសំណូមពរចុងក្រោយបង្អស់ថា: ខ្លួនបានដឹងនូវទោសកំហុសហើយ សុំឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ។

**- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted]ប៊ុន**

**- ក្រោយពីបានស្តាប់ចម្លើយសាក្សី និងអំណានចម្លើយសាក្សី**

**-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារផ្សេងៗក្នុងសំណុំរឿង**

**- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ**

**- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ**

**- ក្រោយពីបានស្តាប់សំណូមពរ និងសម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុន**

## <u>សាលាដំបូងខេត្តកោះកុង</u>

**ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ:**

**<u>យល់ឃើញថា:</u>**

កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង ៧:៣០នាទី មន្ត្រីរបស់មន្ទីរបរិស្ថានខេត្តកោះកុង បានសហការណ៍ជាមួយកងកម្លាំងរាជអាវុធហត្ថលើផ្ទៃប្រទេស និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ បានចុះប្រតិបត្តិការបង្ក្រាបបទល្មើសធនធានធម្មជាតិ ត្រង់តំបន់ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង ចំណុចរបៀងអភិរក្សជីវៈចម្រុះ និយាមកាលេខ: **៣៦១៣៨៣-១២៣៥២៧៩** ស្ថិតនៅភូមិតាផង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង ក៏បានឃើញមានការ **កាប់គាស់ រុករាន ឆ្ការ និងដុតដីព្រៃយកធ្វើជាកម្មសិទ្ធិ** ដែលបង្កឡើងដោយឈ្មោះ [redacted] ប៊ុន ដែលមានផ្ទៃដីទំហំ **0,៣៥** (សូន្យ *កណ្តក់សញ្ញា* **សាមសិបប្រាំ) ហិកតា** ដែលទើបតែកាប់រានថ្មីៗ និងមានការសង់រោងស្នាក់នៅចំនួន **០២រោង** ព្រមទាំងមានដាំដំណាំមួយចំនួនផងដែរ ។ កន្លងមកខាងមន្ត្រីបរិស្ថានធ្លាប់បានចុះទៅណែនាំឈ្មោះ [redacted]ប៊ុន ឲ្យឈប់កាប់រានដីព្រៃបន្តទៀត តែឈ្មោះនោះ មិនស្តាប់ ទើបសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនឈ្មោះ [redacted]ប៊ុន បញ្ជូនមកតុលាការតែម្តង ។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted]ប៊ុន នាពេលសវនាការបានឆ្លើយថា: កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង **០៧ព្រឹក** ខ្លួន និងប្រពន្ធកំពុងនៅផ្ទះ ស្ថិតនៅភូមិតាផង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង ស្រាប់តែសមត្ថកិច្ចមកដល់ហើយធ្វើការឃាត់ខ្លួន រូបខ្លួនតែម្តង ដោយពាក់ព័ន្ធនឹងបទល្មើសព្រៃឈើ ។ ដីដែលស្ថិតនៅចំណុចរបៀងជីវៈចម្រុះ ស្ថិតនៅក្នុងភូមិតាផង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង គឺខ្លួនបានកាន់កាប់រយៈពេល **០៧ឆ្នាំ** មកហើយ ដីនោះមានចំនួន **២ក្បាលដី** គឺមានទំហំ **៤ហិកតា** និង**៦ហិកតា** ដែលមានទីតាំងផ្សេងពីគ្នា តែនៅជិតៗគ្នា សព្វថ្ងៃខ្លួនរស់/



Scanned with CamScanner

នៅលើដីដែលមានក្បាលដី **៤ហិកតា** ចំណែកដីដែលមានក្បាលដី **៦ហិកតា** គឺខ្លួនបានសង់កូនខ្ទមចំនួន០២ ដែលមានដាំដើមស្វាយចន្ទី និងដាំដើមដូង។ ចំពោះដីទាំង ពីរកន្លែងនោះ គឺខ្លួនមិនមានលិខិតកាន់កាប់នោះទេ មានតែលិខិតស្នើសុំទៅអភិបាលខេត្ត ហើយក៏មាន ខាងសុរិយោដីស្រុកស្រែអំបិល ចុះមកវាស់វែងផងដែរ តែក្រោយពីការវាស់វែងខាងសុរិយោដីបានប្រាប់ថា មិនឲ្យខ្លួនកាន់កាប់ដីនោះទៀតទេ រងចាំលិខិតអនុញ្ញាតមកពីខាងអាជ្ញាធរសិន នៅអំឡុងឆ្នាំ២០១៩ ខាងបរិស្ថានធ្លាប់បានចុះមកហាមឃាត់ខ្លួនមិនឲ្យធ្វើការកាប់ព្រៃឈើ តែក្រោយពេលដែលខាងបរិស្ថានចុះមកបានប្រហែលជា៥ ទៅ ៦ថ្ងៃ ខ្លួនបានទៅកាប់ឆ្ការព្រៃជុំវិញដើមស្វាយចន្ទី អស់ដីប្រហែល **០៣អា** ខ្លួនបានដឹងថាការកាប់ព្រៃឈើជាអំពើល្មើសនឹងច្បាប់ ។

-តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌, ចម្លើយសាក្សី និងកំណត់ហេតុដកហូតវត្ថុតាង មានភាពស៊ីសង្វាក់គ្នាអាចកំណត់បានថា: [redacted]ប៊ុន ភេទប្រុស អាយុ ៦៥ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តបទល្មើស **កាប់គាស់ រុករាន ឆ្ការ និងដុតដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅតំបន់ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង ចំណុចរបៀងអភិរក្សជីវៈចម្រុះ ត្រង់និយាមការលេខ: **៣៦១៣៤៣-១២៣៥២៧៩** នៅភូមិតាផង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា **៥៦ ចំណុច៤** និងមាត្រា **៦២ ចំណុច១ នៃច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិ** ពិតប្រាកដមែន។

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ: [redacted] ប៊ុន *ពីបទ:* **កាប់គាស់ រុករាន ឆ្ការ និងដុតដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅតំបន់ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង ចំណុចរបៀងអភិរក្សជីវៈចម្រុះ ត្រង់និយាមការលេខ: **៣៦១៣៤៣-១២៣៥២៧៩** នៅភូមិតាផង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា **៥៦ ចំណុច៤** និងមាត្រា **៦២ ចំណុច១ នៃច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិ**។

**-វត្ថុតាងមាន:**

-ផ្ទៃដីទំហំ **០,៣៥ (សូន្យ** *កណ្តក់សញ្ញា* **សាមសិបប្រាំ) ហិកតា** ដែលទើបតែកាប់រានថ្មីៗ និងមានការសង់រោងស្នាក់នៅបណ្តោះអាសន្នចំនួន**០២រោង** ព្រមទាំងមានដាំដំណាំមួយចំនួន ក្នុងតំបន់ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង ចំណុចរបៀងអភិរក្សជីវៈចម្រុះ និយាមការលេខ: **៣៦១៣៤៣-១២៣៥២៧៩** ស្ថិតនៅភូមិតាផង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង ***គប្បីរុះរើ និងបំផ្លាញចោល*** **និងរឹបអូសផ្ទៃដីដែលមានទំហំដូចខាងលើ ទុកជាកម្មសិទ្ធិរបស់រដ្ឋ** តាមមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសាលាដំបូងខេត្តកោះកុង

## វិនិច្ឆ័យសេចក្តី

១/-**ផ្តន្ទាទោស:** ឈ្មោះ: [redacted]ប៊ុន ភេទប្រុស អាយុ ៦៥ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **០៥ឆ្នាំ (ប្រាំឆ្នាំ)** *ពីបទ:* **កាប់គាស់ រុករាន ឆ្ការ និងដុតដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅតំបន់ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង ចំណុចរបៀងអភិរក្សជីវៈចម្រុះ ត្រង់និយាមការលេខ: **៣៦១៣៤៣-១២៣៥២៧៩** នៅភូមិតាផង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៩/



Scanned with CamScanner

បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៥៦ ចំណុច៤ និងមាត្រា ៦២ ចំណុច១ នៃច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិ។

២/-<u>ចត្ថុតាងមាន:</u>

-ផ្ទៃដីទំហំ ០,៣៥ (សូន្យ *កណ្តក់សញ្ញា* សាមសិបប្រាំ) ហិកតា ដែលទើបតែកាប់រានថ្មីៗ និងមានការសង់រោងស្នាក់នៅបណ្តោះអាសន្នចំនួន០២រោង ព្រមទាំងមានដាំដំណាំមួយចំនួន ក្នុងតំបន់ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង ចំណុចរបៀងអភិរក្សជីវៈចម្រុះ និយាមការលេខ: ៣៦១៣៤៣-១២៣៥២៧៩ ស្ថិតនៅភូមិតាផង ឃុំជងពែង ស្រុកស្រែអំបិល ខេត្តកោះកុង *ត្រូវ ដុះបរ៉ និងបំផ្លាញចោល* និងត្រូវរឹបអូសផ្ទៃដីដែលមានទំហំដូចខាងលើ ទុកជាកម្មសិទ្ធិរបស់រដ្ឋ តាមមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣/-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងកំបាំងមុខមេធាវីការពារក្តី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃពុធ ០២កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

កោះកុង , ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០

ក្រឡាបញ្ជីសវនាការ

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner